ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការគណៈរដ្ឋមន្ត្រី
លេខៈ ០៦ សកស

# សេចក្តីសម្រេច
# ស្តីពី
# ការដាក់ឲ្យអនុវត្តស្តង់ដាជាតិសមត្ថភាពកម្រិត២ ចំនួន៧មុខរបរ

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី
## និងជាប្រធានគណៈកម្មាធិការជាតិបណ្តុះបណ្តាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញអនុក្រឹត្យលេខ៦៥ អនក្រ.បក ចុះថ្ងៃទី២៩ ខែមេសា ឆ្នាំ២០០៥ ស្តីពីការបង្កើតគណៈកម្មាធិការជាតិបណ្តុះបណ្តាល
- បានឃើញអនុក្រឹត្យលេខ៤៨ អនក្រ.បក ចុះថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០០៨ ស្តីពីការកែសម្រួលមាត្រា២នៃអនុក្រឹត្យលេខ៦៥ អនក្រ.បក ចុះថ្ងៃទី២៩ ខែមេសា ឆ្នាំ២០០៥ ស្តីពីការបង្កើតគណៈកម្មាធិការជាតិបណ្តុះបណ្តាល
- បានឃើញអនុក្រឹត្យលេខ១០៦៦ អនក្រ.តត ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០០៩ ស្តីពីការតែងតាំងសមាសភាពនៃគណៈកម្មាធិការជាតិបណ្តុះបណ្តាល
- បានឃើញប្រកាសលេខ១៣៥ ប្រក. ចុះថ្ងៃទី១០ ខែតុលា ឆ្នាំ២០០៨ ស្តីពីការបង្កើតអនុគណៈកម្មការស្តង់ដាជាតិសមត្ថភាពនិងធ្វើតេស្ត
- បានឃើញសេចក្តីសម្រេចលេខ៦០ សសរ ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១០ ស្តីពីការតែងតាំងសមាសភាពអនុគណៈកម្មការស្តង់ដាជាតិសមត្ថភាពនិងធ្វើតេស្ត
- យោងស្មារតីអង្គប្រជុំគណៈកម្មាធិការជាតិបណ្តុះបណ្តាល នាថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០១២

## សម្រេច

**ប្រការ ១.-**

ត្រូវបានដាក់ឲ្យអនុវត្តស្តង់ដាជាតិសមត្ថភាពកម្រិត២ ចំនួន៧មុខរបរដូចខាងក្រោម ៖

- ការងារកំបោរ ( ឧបសម្ព័ន្ធទី១ )
- ការដំឡើងសរសៃដែក ( ឧបសម្ព័ន្ធទី២ )
- ការដំឡើងពុម្ព ( ឧបសម្ព័ន្ធទី៣ )
- ការដំឡើងគ្រឿងឈើសម្រេច ( ឧបសម្ព័ន្ធទី៤ )
- ការថែទាំនិងជួសជុលរថយន្ត ( ឧបសម្ព័ន្ធទី៥ )
- ការថែទាំនិងជួសជុលអគ្គីសនីរថយន្ត ( ឧបសម្ព័ន្ធទី៦ )
- ការថែទាំនិងជួសជុលម៉ាស៊ីនត្រជាក់រថយន្ត ( ឧបសម្ព័ន្ធទី៧ )។

ស្តង់ដាជាតិសមត្ថភាពកម្រិត២ ចំនួន៧មុខរបរ មានភ្ជាប់ជាឧបសម្ព័ន្ធនៃសេចក្តីសម្រេចនេះ។

**ប្រការ ២.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសម្រេចនេះត្រូវទុកជានិរាករណ៍។

**ប្រការ ៣.-**

អគ្គលេខាធិការរាជរដ្ឋាភិបាល នាយកខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី អគ្គនាយកនៃអគ្គនាយកដ្ឋានអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈនៃក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈប្រធានគណៈកម្មាធិការបណ្តុះបណ្តាលរាជធានី-ខេត្ត គ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ និងសហគ្រាសគ្រឹះស្ថានទាំងអស់ ត្រូវអនុវត្តសេចក្តីសម្រេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ មករា ឆ្នាំ ២០១៣

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**
**និងជាប្រធានគណៈកម្មាធិការជាតិបណ្តុះបណ្តាល**

**សុខ អាន**

**កន្លែងទទួល:**
- ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ
- គ្រប់សមាជិកគណៈកម្មាធិការជាតិបណ្តុះបណ្តាល
- ដូចប្រការ ៣
- ឯកសារ- កាលប្បវត្តិ